ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២៨៤ ម.ឧ.ធាប.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ និងបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ និងប្តូរដល់យានយន្ត

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល


លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់បទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជី (LPG) (ហ្គាស) ក្នុងកំប៉ុងឬធុងដើម្បីលក់ និងបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិប្រេងរំអិលក្នុងកំប៉ុងឬធុងដើម្បីលក់និងប្តូរដល់យានយន្ត សំដៅលើកកម្ពស់សុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈ។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅកំណត់បទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិ៖

- ឧស្ម័នអិលភីជី (LPG) (ហ្គាស) ក្នុងកំប៉ុងឬធុងដើម្បីលក់
- ប្រេងរំអិលក្នុងកំប៉ុងឬធុងដើម្បីលក់និងប្តូរដល់យានយន្ត

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការធ្វើសន្និធិ៖

- ឧស្ម័នអិលភីជី (LPG) (ហ្គាស) ក្នុងកំប៉ុងឬធុងដើម្បីលក់ ប៉ុន្តែមិនអនុវត្តទៅលើ៖
  - ការលក់ឧស្ម័នអិលភីជី ចាក់ឱ្យយានយន្ត ឬស្ថានីយចាក់ឧស្ម័នអិលភីជី
  - ការបញ្ចូលឧស្ម័នអិលភីជីចូលក្នុងធុង និង/ឬក្នុងកំប៉ុង
  - ទីតាំងត្រួតពិនិត្យរូបលក្ខណៈ និងសាកសម្ពាធធុងឧស្ម័នអិលភីជី
  - ទីតាំងអាជីវកម្មលក់ឧស្ម័នប្រភេទផ្សេងទៀត ក្រៅពីឧស្ម័នអិលភីជី។
- ប្រេងរំអិលក្នុងកំប៉ុងឬធុងដើម្បីលក់និងប្តូរដល់យានយន្ត

**ប្រការ៤ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពលក់ឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុង ត្រូវគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុងដូចខាងក្រោម៖

**ក. លក្ខណៈបច្ចេកទេសរបស់សំបកកំប៉ុង និងធុងផ្ទុកឧស្ម័នអិលភីជី**

- សំបកកំប៉ុងផ្ទុកឧស្ម័នអិលភីជីយកមកលក់ ត្រូវធ្វើពីលោហធាតុដែលអាចធន់នឹងសម្ពាធ ហើយមានចំណុះចាប់ពី ៣០០ ក្រាម (ក្រ) ចុះក្រោម។
- សំបកធុងដែលផ្ទុកឧស្ម័នអិលភីជីត្រូវមានចំណុះចាប់ពី ៤៨ គីឡូក្រាម (គ.ក្រ) ចុះក្រោម។



៥

## ខ. ទីតាំងឃ្លាំង/ស្តង់សន្និធិដើម្បីលក់

- ទីតាំងឃ្លាំង/ស្តង់ស្តុកទុកធុងឧស្ម័នអិលភីជីត្រូវស្ថិតនៅជាន់ផ្ទាល់ដីរាបស្មើ ស្ងួត រឹងមាំ ខ្ពស់ជាង ឬស្មើទីតាំងនៅជុំវិញ។
- ទីតាំងឃ្លាំង/ស្តង់ស្តុកទុកនេះត្រូវមានសសរនិងជញ្ជាំងធ្វើពីធាតុមិនងាយឆេះ មានកម្ពស់យ៉ាងតិច ១,៨០ ម៉ែត្រ មានដំបូលដែលធ្វើពីធាតុមិនងាយឆេះ និងមានប្រព័ន្ធរន្ធខ្យល់ចេញចូលផ្នែកខាងលើនិងខាងក្រោម។
- ទីតាំងឃ្លាំង/ស្តង់ ត្រូវស្ថិតនៅចម្ងាយពីជញ្ជាំងលំនៅដ្ឋានអ្នកជិតខាង ឬព្រំរបងនៃការដ្ឋានដែលស្ថិតនៅក្បែរខាង ដូចខាងក្រោម៖

| **បរិមាណសន្និធិសរុប (គ.ក្រ)** | **គ្មានជញ្ជាំងសុវត្ថិភាព (ម៉ែត្រ)** | **មានជញ្ជាំងសុវត្ថិភាព (ម៉ែត្រ)** |
|---|---|---|
| ចាប់ពី ៥០០ ចុះក្រោម | ០ | ០ |
| ពី ៥០១ ដល់ ១ ០០០ | ៣ | ១ |
| ពី ១ ០០១ ដល់ ៤ ០០០ | ៤ | ១ |
| ពី ៤ ០០១ ដល់ ៦ ០០០ | ៥ | ១ |
| ពី ៦ ០០១ ដល់ ១២ ០០០ | ៦ | ២ |
| ពី ១២ ០០១ ដល់ ២០ ០០០ | ៧ | ២ |
| ពី ២០ ០០១ ដល់ ៣០ ០០០ | ៨ | ៣ |
| ពី ៣០ ០០១ ដល់ ៥០ ០០០ | ៩ | ៣ |
| ពី ៥០ ០០១ ដល់ ៦០ ០០០ | ១០ | ៤ |
| ពី ៦០ ០០១ ដល់ ១០០ ០០០ | ១១ | ៤,៥០ |
| ពី ១០០ ០០១ ដល់ ១៥០ ០០០ | ១២ | ៥ |
| ពី ១៥០ ០០១ ដល់ ២៥០ ០០០ | ១៥ | ៦ |
| លើសពី ២៥០ ០០០ | ២០ | ៧ |



៤

- ទីតាំងឃ្លាំង/ស្តង់ ត្រូវស្ថិតនៅចម្ងាយពីសារធាតុគ្រោះថ្នាក់ដូចខាងក្រោម៖

| **ប្រភេទសារធាតុ** | **ចម្ងាយ (ម៉ែត្រ)** |
|---|---|
| ធុងខ្យល់បំពែន | ៣ |
| ធុងអាសេទីឡែន | ៣ |
| ធុងសារធាតុដែលអាចឆាបឆេះ | ៣ |
| សារធាតុងាយឆេះ ពុល និងច្រែះស៊ី | ៣ |
| អុកស៊ីសែនរាវ | ៧,៥០ |

- ទីតាំងដែលជាផ្ទះល្វែងមួយល្វែងស្ថិតនៅជាប់ៗគ្នា មិនអនុញ្ញាតឱ្យមានការស្តុកទុកឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុងដើម្បីលក់លើសពី ៥០០ គ.ក្រឡើយ។
- ត្រូវបំពាក់ឧបករណ៍ចាប់ការលេចធ្លាយឧស្ម័នអិលភីជីនៅខាងក្នុងឃ្លាំង/ស្តង់ ដោយមានគម្លាតប្រវែង ១,៥ ម៉ែត្រ ពីទីតាំងតម្កល់កំប៉ុង ឬធុងឧស្ម័នអិលភីជី និងដោយមានកម្ពស់ ពីផ្ទៃបាតមិនឱ្យលើសពី ៣០ សង់ទីម៉ែត្រ។
- ត្រូវមានមធ្យោបាយលើកដាក់ធុងឧស្ម័នអិលភីជីគ្រប់គ្រាន់ (ដូចជាប្រដាប់ស្ទូច ខ្សែពួរ និង/ឬ រទេះ ជាដើម) មិនត្រូវទាញ អូស រមៀលចុះ ឬទម្លាក់ធុងឧស្ម័នអិលភីជីទេ។
- ត្រូវមានឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យស្របតាមការកំណត់របស់អង្គភាពពន្លត់អគ្គិភ័យ។
- ត្រូវបិទស្លាកសញ្ញាហាមជក់បារី និងសេចក្តីណែនាំស្តីពីសុវត្ថិភាពផ្សេងៗ ឱ្យបានគ្រប់គ្រាន់។
- ទ្វារចេញ-ចូលនៃទីតាំងឃ្លាំង/ស្តង់ត្រូវជាទ្វារចម្រឹង ឬសំណាញ់ដែកសម្រាប់ឱ្យខ្យល់បរិយាកាសចេញ-ចូលបានគ្រប់គ្រាន់។
- មិនអនុញ្ញាតឱ្យធ្វើការបញ្ចូលឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុងនៅទីតាំងឃ្លាំង/ស្តង់លក់ឡើយ។

## គ. ការរៀបចំតម្កល់ទុកកំប៉ុង និងធុងឧស្ម័នអិលភីជី

- ធុងឧស្ម័នអិលភីជីទាំងអស់ត្រូវរៀបចំតម្កល់នៅក្នុងឃ្លាំង/ស្តង់ ដោយមិនត្រូវដាក់នៅបាំងផ្លូវដើរឆ្លងកាត់ ឬច្រកចេញ-ចូលទេ។ ក្នុងករណី៖
    - មានផ្លូវចេញចូលតែមួយ ត្រូវមានទទឹងផ្លូវអប្បបរមាប្រវែង ៣ ម៉ែត្រ
    - មានផ្លូវចេញចូលលើសពីមួយ ត្រូវមានទទឹងផ្លូវអប្បបរមាប្រវែង ១,៥០ ម៉ែត្រ
    - ទទឹងផ្លូវចេញចូលមិនអាចអនុវត្តបានដូចចំណុចទាំងពីរខាងលើ ត្រូវសង់ជញ្ជាំងដែល

ធន់នឹងអគ្គិភ័យបានរយៈពេលយ៉ាងតិច២ម៉ោង និង មានកម្ពស់អប្បបរមា ១,៨ ម៉ែត្រ។

- ធុងឧស្ម័នអិលភីជីត្រូវស្ថិតនៅចម្ងាយយ៉ាងហោចណាស់ឱ្យបាន ១,៥០ ម៉ែត្រ ពីបង្អួច ទ្វារ ឬរន្ធខ្យល់ចេញ-ចូលនៃឃ្លាំង/ស្តង់។
- កំប៉ុងនិងធុងឧស្ម័នអិលភីជីដែលស្តុកទុកទាំងអស់ ត្រូវតែគ្របក្បាលស៊ូប៉ាប់ និងមួលវ៉ានបិទជិតជានិច្ច។
- ធុងឧស្ម័នអិលភីជីដែលមានផ្ទុកឧស្ម័នអិលភីជី និងធុងឧស្ម័នអិលភីជីដែលមិនមានផ្ទុកឧស្ម័នអិលភីជីត្រូវទុកដាក់យ៉ាងណាឱ្យនៅដាច់ពីគ្នា។
- ធុងឧស្ម័នអិលភីជី និងឧបករណ៍គ្រឿងបន្លាស់ទាំងអស់ដែលមាននៅកន្លែងលក់ ត្រូវរៀបចំឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

**ប្រការ៥ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពលក់ និងប្តូរប្រេងរំអិលក្នុងកំប៉ុងឬធុង ត្រូវគោរពតាមបទប្បញ្ញត្តិបច្ចេកទេស សុវត្ថិភាពសន្និធិប្រេងរំអិលក្នុងកំប៉ុងឬធុង ដូចខាងក្រោម៖

**<u>ក. ឃ្លាំងសន្និធិ (ទុកដាក់) ប្រេងរំអិល</u>**

- ត្រូវមានឧបករណ៍សម្ភារៈលើកដាក់និងដឹកជញ្ជូន (ប្រដាប់ស្ទូច បន្ទះក្តារឈើ ឬដែក និងរទេះជាដើម) គ្រប់គ្រាន់ក្នុងការរើធុង (ធុងដែក ឬធុងជ័រ) និង/ឬកំប៉ុងប្រេងរំអិលពីយានយន្តដឹកមកទុកដាក់ក្នុងឃ្លាំង និងទីតាំងតាំងលក់។
- ត្រូវមានជើងទម្រធ្វើអំពីឈើឬដែកដែលរឹងមាំសម្រាប់ដាក់ធុង ឬកេសប្រេងរំអិលបញ្ឈរត្រង់ចៀសវាងដួលរលំ ឬរមៀល។
- ប្រើកំប៉ុង ឬធុងដែលមានចំណុះ ចាប់ពី ឬស្មើ ២០០ លីត្រ ចុះក្រោម។
- ត្រូវមានកេសសម្រាប់តម្រៀបកំប៉ុងប្រេងរំអិល និងត្រូវដាក់នៅលើជើងទម្រ។
- ជើងទម្រមួយ មិនត្រូវដាក់កេសដាក់កំប៉ុងប្រេងរំអិលចំណុះ ៥ លីត្រ ត្រួតលើគ្នា លើសពី ៦ ថ្នាក់ឡើយ។
- ជើងទម្រមួយ មិនត្រូវតម្រៀបធុងប្រេងរំអិលចំណុះ ១៨ លីត្រ ឬ២០លីត្រ ត្រួតលើគ្នាលើសពី ៣ ថ្នាក់ឡើយ។
- ត្រូវរៀបចំទុកដាក់ធុងប្រេងរំអិលនៅក្នុងឃ្លាំង ឬអគារ ប្រសើរជាងការទុកដាក់នៅទីវាល។ ក្នុងករណីទុកដាក់ធុងប្រេងរំអិល (ធុងដែក) នៅទីវាល ត្រូវមានរោងប្រក់ដំបូលសម្រាប់ ការពារ

សំណើម ទឹកភ្លៀង និងកំដៅថ្ងៃ។

- ត្រូវមានបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យ និងធុងខ្សាច់គ្រប់គ្រាន់។
- មិនត្រូវបង្ហូរកាកសំណល់ប្រេងរំអិលចូលក្នុងប្រព័ន្ធលូសាធារណៈ។
- មិនត្រូវទុកដាក់ទំនិញផ្សេងទៀតនៅលាយឡំជាមួយធុង ឬកំប៉ុងប្រេងរំអិលទេ ដោយត្រូវសង់ជញ្ជាំងខណ្ឌផ្តាច់ពីទំនិញទាំងនោះ។
- ហាមទំលាក់ធុង ឬកំប៉ុងពីយានយន្តមកដី។
- ត្រូវទុកដាក់ធុង ឬកំប៉ុងប្រេងរំអិលឱ្យមានចម្ងាយអប្បបរមា ១ ម៉ែត្រ ពីដំបូលឃ្លាំង ឬរោង។

**ខ. ទីតាំងតាំងលក់ និងប្តូរប្រេងរំអិល**

- ត្រូវមានទីធ្លាទូលាយនិងខ្យល់ចេញចូលបានល្អ និងស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រ ពីប្រភពបញ្ឆេះ។
- ត្រូវរៀបចំទុកដាក់កំប៉ុង ឬធុងប្រេងរំអិលនៅក្នុងទីតាំងលក់ឱ្យមានរបៀបរៀបរយនិងដាច់ដោយឡែកពីទំនិញផ្សេងទៀត ។
- ត្រូវមានកន្លែងសម្រាប់ប្រមូលទុកសំបកធុង ឬសំបកកំប៉ុងប្រេងរំអិលដែលប្រើរួច។
- ត្រូវមានធុងសម្រាប់ប្រមូលទុកដាក់ប្រេងរំអិលចោលដែលត្រូវបានប្តូរចេញពីម៉ាស៊ីនយានយន្ត។
- ត្រូវសម្អាតទីតាំងប្តូរប្រេងរំអិលឱ្យបានស្អាតពីការប្រឡាក់ ឬកំពប់ប្រេងរំអិល។
- ត្រូវប្រើថាសដែលមានមាត់ធំទូលាយ ដើម្បីដាក់ត្រងសំណល់ប្រេងរំអិលដែលប្តូរ និងត្រូវដាក់ទ្រនាប់បឺតប្រេងរំអិលនៅខាងក្រោម។
- ត្រូវមានវត្ថុបឺត ឬជក់ប្រេង ដើម្បីបង្ការពេលមានកំពប់ប្រេងរំអិល និងត្រូវមានធុងសម្រាប់ប្រមូលទុកដាក់សំណល់វត្ថុបឺត ឬជក់ប្រេងនោះ។
- ត្រូវមានឧបករណ៍ពន្លត់អគ្គិភ័យ និងធុងខ្សាច់គ្រប់គ្រាន់។
- មិនត្រូវបង្ហូរកាកសំណល់ប្រេងរំអិលចូលក្នុងប្រព័ន្ធលូសាធារណៈ។

**ប្រការ៦ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបអាជីវកម្មលក់ឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុង និង/ឬដែលធ្វើអាជីវកម្មលក់និងប្តូរប្រេងរំអិលក្នុងកំប៉ុងឬធុងទាំងអស់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានកំណត់ក្នុងប្រការ ៤ និងប្រការ ៥ នៃប្រកាសនេះ។



៥

**ប្រការ៧ .-**

បទប្បញ្ញត្តិបច្ចេកទេសកំណត់ក្នុងប្រកាសនេះ នឹងត្រូវធ្វើការកែសម្រួល និងបញ្ចូលបន្ថែមនូវលក្ខណៈបច្ចេកទេសសុវត្ថិភាពចាំបាច់ផ្សេងទៀត តាមស្ថានភាពវិវឌ្ឍជាក់ស្តែងនៅពេលអនាគត។

**ប្រការ៨ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី-ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលទទួលបានការប្រគល់មុខងារ អាជីវករលក់ឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុង និងអាជីវករលក់និងប្តូរប្រេងរំអិលក្នុងកំប៉ុងឬធុងទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមាន ប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៣រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ-សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ